Khmer Story Lovers


# បញ្ញាមរណៈ

ប្រលោមលោកប្រឌិតតាមសម័យបុរាណ ចិន

ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ




**វគ្គទី ៧**

## នាយក្រុមឈានល្ង

តាចាស់ឈ្មោះ ពៅហាស៊ី បានធ្វើជាគ្រូពេទ្យដៃឆើតមែន ៗ លុះស្ត្រីបានឮហៅឈ្មោះដូច្នេះ គាត់តក់ស្លុតណាស់, ក្អកខ្វះៗតបថា:

–អរគុណ ខ្ញុំមិនសមនឹងធ្វើជាគ្រូពេទ្យដៃឆើតទេ សូមលោកស្រីកុំនិយាយលើសពេក ៗ

យានទីបន្ត:

–ខ្ញុំឮល្បីថា លោកគ្រូពេទ្យទៅណាមកណា ដើម្បីស្រោចស្រង់ជីវិតមនុស្សតែម្នាក់ឯងទេ ៗ តើលោកគ្រូចូលជាសមាជិកក្រុមឈានល្ងពីអង្កាល់ ?

ពៅហាស៊ីញញឹម :

– មនុស្សម្នាក់រូបទោះពូកែយ៉ាងណា ក៏មិនអាចជួយគេគ្រប់ទិសទីបានដែរ ដូច្នេះទាល់តែរួបរួមគ្នាណា ៗ លោកស្រី យើងខ្ញុំមកកាន់ទីនេះដោយបុកតាមិនសូវសមរម្យ សូមលោកដែលមានចិត្តទូលាយមេត្តាអនុគ្រោះផងចុះ ទេះ ។ បើគ្មានការពួកយើងមិនមករំខានលោកទេ តែនេះរឿងធំណាស់ ៗ ពួកយើងខ្ញុំចង់សុំជួបលោកនាយក្រុម សូមលោកអាណិតជួយនាំ


អ្នកប្រែសម្រួល: អ.គឹមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ៧

ទៅផង!

សើយានចំស្ងើរទាំងឆ្ងល់ :

– លោកនាយក្រុម អស់លោកជាអ្នកណា ? ខ្ញុំចាកចោលពិភពគុនយូរហើយ សូម្បីឈ្មោះនាយក្រុមនោះក៏មិនស្គាល់ដែរ តើឲ្យខ្ញុំនាំទៅជួបគេឯណា ?

គ្រាន់តែឮសំដីនេះភ្លាម ពួកឈានល្ហួធ្វើមុខមាំភ្លាម ៗ តៃហាស៊ីច្បូតពុកមាត់ក្អកខេះ ១ ពោលបន្ត.

– លោកសើ នាយក្រុមត្រកូលស៊ីយើងខ្ញុំបានចងមិត្តជាមួយលោក យើងខ្ញុំគោរពលោកណាស់ មិនហ៊ានខ្វះការគួរសមទេ ៗ ឯដំណើរនៃនាយក្រុមស៊ីវិញ យើងខ្ញុំជាអ្នកតូចតាច មិនហ៊ានចង់ដឹងអ្វីទេ តែលោកនាយក្រុមបានចាកចេញពីជំរំយូរណាស់ហើយ ហើយមានកិច្ចការជាច្រើនរង់ចាំគាត់ទៅសម្រេច ម្យ៉ាងទៀតពេលនេះ ក្រុមយើងខ្ញុំបានជួបប្រទះបញ្ហាដ៏ពិបាកពីរដែលតម្រូវឲ្យលោកនាយក្រុមទៅចាត់ចែងផ្ទាល់ដៃ... ខេះ ១... ហេតុនេះគ្រាន់តែទទួលដំណឹងថាលោកនាយក្រុមនៅភ្នំមីដានភ្លាម ក៏ប្រញាប់មករកជាបន្ទាន់ដែរ ដើម្បីអញ្ជើញគាត់ត្រឡប់ទៅវិញ ៗ

សើយានចំពួគោពាលយ៉ាងស្មោះត្រង់ ហើយមើលបុគ្គលជនទាំង ៩ ទោះកាន់អាវុធ ក៏ហាក់ដូចគ្មានបំណងអាក្រក់ដែរ ក៏ស្មានថាពួកនេះប្រហែលច្រឡំហើយទើបតបតាមសម្រួលៈ

– លើភ្នំមីដានគ្មានគុកៅអីសម្រាប់ទទួលភ្ញៀវមកពីឆ្ងាយទេ សូមអស់លោករើសកន្លែងគួរសមតាមចិត្តចុះ ៗ តើលោកគ្រូពួនណាប្រាប់ថា ខ្ញុំជាមិត្រនឹងនាយក្រុមលោក? ក្រុមឈានល្ហួមានសមាជិកកុះករហើយក្លាហានផង ដូច្នេះនាយក្រុមស៊ីប្រហែលជាកំពូលអ្នកគុននិយមដ៏ល្បីល្បាញហើយ ៗ ឯខ្ញុំបានចាកចេញពីពិភពគុនយូរហើយ ធ្វើម្តេចនឹងអាចសាងមិត្តភាពជាមួយលោកនាយក្រុមស៊ីកើត ? ហ៊ុះ! ហ៊ុះ! ពិតជាគួរអស់សំណើចមែន!

តៃហាស៊ីពិចារណា :

–បើគេពិតជាបដិសេធថាមិនស្គាល់លោកនាយក្រុមមែន ច្បាស់ជាមានអាថ៌កំបាំងអ្វីទាក់ទងដល់លោកនាយមិនខាន ៗ

បន្ទាប់មកគាត់លើកដៃស្រែកថា :

- បងប្អូនទាំងអស់ អង្គុយចុះមកនិយាយគ្នា!

តៃហាស៊ីច្រហៃលជាមេដឹកនាំពួកចាំងនេះហើយ ព្រោះចប់សំដីគាត់ភ្លាមពួកគេក៏អន្ទ្រយចុះចាំងអស់គ្នាដែរ ។ ពួកឈានលួនៅតែពួនគ្នាអន្ទ្រយព័ទ្ធជុំវិញសេីយានទឹដដែល ។ យានទឹខឹងក្រេវមួយរំពេចចំពោះអាកប្បកិរិយាប្រមាថមើលងាយនៃពួកនេះ ។ គាត់នឹកក្នុងចិត្ត:

– កុំថាឡើយយើងមិនដឹងនាយក្រុមពួកឯងនៅកន្លែងណា ទោះជាដឹងក៏យើងមិនអាចកំយ ពុំប្រាប់តាមរបៀបនឹងដូច្នេះដែរ ។

គិតដូច្នេះហើយ គាត់គ្រហឹមហ៊ឹះ ងើយមើលព្រះអាទិត្យធ្វើហី ។

លោកគ្រូពេទ្យដែលើតមានឋានៈខ្ពង់ខ្ពស់ស្មើសេីយានទឹ ដូច្នេះអាកប្បកិរិយាម្ចាស់ក្លឹម៉ាកានពេលនេះក៏ពុំសូវសមរម្យដែរ ។ តែមកនឹកថាគេជាមិត្ររបស់នាយក្រុមខ្លួន ម្ល៉ោះហើយគាត់បន្ទឹកតាយ៉ាងទន់ភ្លន់ ថា

– លោកសេី តាមពិត, នេះជាកិច្ចការផ្ទុក្ខនៃក្រុមខ្ញុំទេ តែធ្វើម៉េចបើវាមានទាក់ទងនឹងលោក ឲ្យតែលោកមេត្តានាំពួកយើងទៅជួបលោកនាយក្រុមដូចក្តីប្រាថ្នា យើងខ្ញុំនឹងគោរពសុំអភ័យទោសពីលោកភ្លាម ។

តាមធម្មតា តៃហាស៊ីមិនដែលពោលពាក្យយ៉ាងស្រគតស្រគំមានរបៀបពេសាទៅកាន់អ្នកណាទេ ដូច្នេះសឲ្យឃើញថា ពេលនេះគាត់គោរពយានទឹណាស់ ។

ម្ចាស់បញ្ញាដែកសំរិទ្ធសួរថា :

– លោកគ្រូពេទ្យ ! លោកជាអ្នកក្លាហានពិត្យ ហើយថ្លៃថ្នូរណាស់មែនទេ ?

តៃហាស៊ីឮសំដីពោរពេញដោយការតក្តៅក្រហាយ ក៏ប្រុងប្រយ័ត្នហើយតប :

– មិនហ៊ានទេ !

យានទឹបន្ត :

– សំដីលោកគ្រូជាពាក្យសច្ចៈ ឯសំដីខ្ញុំជាពាក្យកុហកឬ ? ខ្ញុំប្រាប់ហើយថាមិនធ្លាប់ស្គាល់នាយក្រុមស៊ីទេ តែអស់លោកនៅតែមិនព្រមជឿទៀត ! ឬ មួយលោកជាអ្នកត្រឹមត្រូវ ហើយចំណែកខ្ញុំជាមនុស្សថោកទាបខុសយស និយាយតែពាក្យឥតខ្លឹមសារបោកប្រាស ?

តៃហាស៊ីក្អកខេះៗ :

– សំដីលោកធ្ងន់បន្តិចហើយ ព្រោះយើងខ្ញុំគោរពលោកណាស់ ។ បើលោកមិន

ព្រមនាំយើងទៅជួបលោកនាយក្រុម យើងខ្ញុំសុំច្បាប់ដើរ រកឲ្យបានសច្ចគ្រប់សិនទើបអស់ចិត្ត ។

សៃយានទីឡើងមុខទៀត:

- លោកគ្រូពេទ្យមិនជឿសំដីហើយថែមចង់ប្រព្រឹត្តអំពើមិនគប្បីក្នុងទីលំនៅខ្ញុំទៀតឬ ?

តៃហៃស៊ីគ្រីក្សាល :

- មិនមែនខ្ញុំប្ដូរទោសលោក ។ យើងខ្ញុំមិនគួររំខានអ្នកផងទេឡើយ តែលោកជួយគិតមើលចុះ ខាយក្រុមឈានល្បួកខ្លួន សមាជិកទាំងអស់គេមិនឃើញថៃរជាពីងពាក់អ្នកក្រៅ មិនឲ្យអ្នកគុននិយម សើចយេះខាត់ ? យើងខ្ញុំងំរកខ្លួនឯងទាល់តែឃើញណា ! មិនមែនប្រព្រឹត្តផ្ដេសផ្ដាសទេ ។

សៃយានទីសញ្ញាំងគិត :

-នៅក្នុងពានក្លួចខាយក្រុមខ្មោចយកឯណាទេ, ពួកឯងព្រហើនណាស់ បានយកលេសនេះចង់-នែកនោរយ៉ាំងយើង ។ មិនអីទេ យើងនឹងស៊ីងពួកឯងប្តូរស្នាបរសម្តងពោះដោយវិធីណាក៏ដោយ ។

គាពាស់ទីនឹកជាគ្រាន់តែតៃហៃស៊ីវាត់កំគួរការម្តៅហើយ, ចុះទំពុំគ្នាគេ ៨ នាក់ទៀត គិតយ៉ាងម៉េចវិញ ? បង្ហាំផ្ទះខ្លួនពិតជាមិនសំរេចបានឡើយ ។

នៅពេលសញ្ញាំងគិតនោះ គាត់ធ្វើជាសម្លឹងមើលទៅឆ្ងាយមិនដាក់ភ្នែក ហាក់ឃើញព្រឹត្តិការណ៍ចម្លែក, រួចធ្វើក្បាក់ផ្អើលលាន់មាត់ថា ! សត្រូវទាំង៩ នាក់ងាកក្បាលទៅមើលដែរ ។សៃយានទីបង្កើរខ្លួនស្ទុះរឹងទៅរកដងសំពងគ្រគូលឹ លូកដៃផកដាវពីចង្កេះគេភ្លាម ។ ដងសំពងក្រឡេកតាមយានទីដកឃើញរឿយ ងាកមកវិញមិនទាន់ត្រូវខ្យល់ដែបក់ពីក្រោយ ហើយចាប់អារម្មណ៍ថាមាននរណាចាប់ដងដាវជាប់ស្រេច ។ គេលូកដៃដណ្តើមវិញយ៉ាងរហ័ស ។ ក្តស្ទួរខ្លាក, កាំបិតប្តូតពីស្រោម ទណ្ឌឹស្តីកាំងពីក្រោមមៀកដល់ក្លឹងខ្លង ព្រោះយានទីលូកដៃចុចជីពចរត្រដែបទាំងចាប់ច្បាមខ្លួនជាប់ទៀត ។

សៃយានទីធ្លាប់ឃើញស្នាដៃដងសំពង កាលប្រយុទ្ធជាមួយខ្មោចតាតែងនឹងកាត់ផ្ដាវកាត់សត្វក្បាលមាណពអ្នកនគាត់ទើបពេលនេះគាត់ភ្ញៀតបង្ក្រាបគេមុនបង្អស់ ដោយប្រើកលល្បិចតាមនឹកឃើញៗ ឥឡូវបានលទ្ធផលជួបចិត្តហើយគាត់សើចហ៊ឹះៗ :

- សូមលោកនីអភ័យទោសណា !

តៃហៃស៊ីប្រញ្ញូងកាំង:

- លោកសែរ៉ិធ្វើម៉េចអ៊ីចឹង ? លោកមិនអនុញ្ញាតឲ្យពួកយើងស្វែងរកលោកនាយក្រុមទេឬ ?

-ពួកឯងចង់សម្លាប់យើងងាយទេ ! តែយើងត្រូវនាំពួកឯងខ្លះទៅគាល់មច្ចុរាជដែរណា !

ពៃហស៊ីសើចស្លូត :

- យើងគ្មានគំនុំអ្វីនឹងគ្នាទេ ម៉េចលោកបានប្រែសាសនទៅបែបហ្នឹង ? ម្យ៉ាងទៀតលោកពូកែណាស់ មិនហ៊ានធ្វើអីលោកទេ, យើងជាមិត្តនឹងគ្នាទេតើ ! សូមលែងផ្លូវ ន៏ ផង ។

-ពៃហស៊ីពោលដូច្នេះ ព្រោះញញើត សែរ៉ិយានទី ត្រង់ចាប់ផ្ដួលបំបាក់បានក្នុងមួយស្មៀតគត់ តែគាត់សន្និដ្ឋានថាជាកលល្បិចមិនត្រឹមត្រូវទេ ។ យានទីចេះវិជ្ជាវិសេសណាស់, គាត់ដឹងច្បាស់ថាចាប់ខ្ញុំបានប៉ុណ្ណេះហើយឲ្យតែផងសំគមហ៊ានរើបំរះ, គាត់បញ្ចេញកម្លាំងកាយមកក្រាប នឹងផាច់សរសៃឈាមស្លាប់មួយរំពេច ។

បានតែប៉ុណ្ណេះហើយ យានទី ពោល :

- អស់លោកហាក់ចេញពីក្ដីមានទៅ យើងលែងមិត្តនេះឲ្យមានសេរីភាពភ្លាម ។

ពៃហស៊ីតប :

- ចុះទៅវិញជាការងាយទេ តែ . . . ប្រក្រតីចុះទៅល្អាចពាចទៀងមកលើវិញណា !

សែរ៉ិយានទីងាក់ក្រញូមុខ :

- លោកត្រូវចេះតែបកវិញនទំពាល់ពោលដូច្នេះ តើមានចម្ងល់ដូចម្ដេចដែរ ?

- អ៊ីអឹងយើង ! មានចម្ងល់យ៉ាងណាសួយជកបលោកដឹងបើក !

ដងកាត់ពៅទាក់ផែលោកមិនស្ងៀមយូរហើយ ទើបប្រាប់គ្នា :

- ពួកយើងនឹងជួយលោកនាយក្រុមដើម្បីរំដោះលោកគ្រូឡប់ទៅដីវិញ

សែរ៉ិយានទីទឹងក្រោធនិយាយសួរ :

- និយាយទៅបក, ឯងរកឈ្មោះបំបេះប៉ាយើងចាប់នាយក្រុមឯងមកឃុំទុកលើភ្នំប៉ាងនេះឬ ?

ពៃហស៊ីតប :

- បើមិនទាន់បានជួបមុខលោកនាយក្រុមពួកយើងមិនហ៊ានចោទលោកផ្ដេសផ្ដាសទេ ។

ពោលចប់គាត់ងាកទៅគូកនប្អាក់ហាដូចជាកូតគេ បញ្ជា :

- ប្អូនយើងទាំងគ្នា យើងរើរកឲ្យសព្វ កាលណាយើងរកនាយក្រុម, គេបកក្រោមប់ចំភ្លាម !

ជនត្រកូលយីនលំទុនកាយ រួចចូលគូកន :

– មករឿយកនយើង ,  លោកគ្រូប្រើឲ្យទៅរកលោកនាយក្រុម !

ជនទាំង ៦ នាក់ស្រែកហ៊ោកេង រួចដើរក្រោកឈរផុតបន្តិចទើបតែបែកខ្ញែកគ្នាអស់ ។ សៃយានខីចាប់ប្លាមខ្លួនគ្នាគេម្នាក់មែន តែមិនឃើញគេឈឺក្បាលទីងជនត្រកូលនីសោះក៏ទឹកឆ្ងល់ជាខ្លាំង ។ តៃហស៊ុនៅជិតនេះឥតប្រុងការពារជនសំគមទេ គាត់គ្រាន់តែឃ្លាំមើលខ្លាចសៃយានខីរត់បាត់ប៉ុណ្ណោះ ។ គាចាស់ត្រកូលសៃមិនមែនល្ងង់អី? គាត់យល់ថ្លុះថៃរបានជាសម្ងំគិតរិះគេមធ្យោបាយរំដោះខ្លួន ។

គាត់ចាំពួកឈានល្អចេញផុតបាត់ស្រមោល ទើបលូកដៃឆ្វេងទៅចង្កេះ ជនសំគមពីក្រោយ ដើម្បីកញ្ចៀញតៃហស៊ុ ។ នេះជាមធ្យោបាយចុងក្រោយរបស់សៃយានខី ព្រោះគាត់យល់ថាវៀងប៉ុសកម្លោះឥតត្រកូលប្រគល់បញ្ហាដែកសំរិទ្ធឲ្យគាត់នោះ ផ្តិលពេញពិតគុនទៅហើយ ។ បើក្រុមឈានល្អ កុំគេសង្ស័យព្រោះឃើញបុរសកម្លោះ, ក្នុងនេះពិតជាចាប់រំលើកវរុធប៉ុន្មាន ដើម្បីប្រហារគាត់មិនខាន ។ គាត់ដឹងប៉ុណ្ណឹងទៀតថា តៃហស៊ុ មានកម្លាំងស្ទុកស្ទួមែន តែឥឡូវឈឺកុំរំច្រើនឆ្នាំទាល់តែគេហៅ «គ្រូពេទ្យដៃធេក» ច្បាស់ជារេះខ្សោយជាងមុនឆ្ងាយណាស់ ឃើញតែក្អកខះៗ មុខស្លេកស្លាំងក៏អាចយល់ដែរ ។

ប្រហែល ១០ ឆ្នាំមុនតៃហស៊ុសម្លាប់មេចោរព្រៃកាចម៉ូរូបតែគ្នាមួយយប់គត់ ល្បីឲ្យព្រួយពិភពគុនទាំងមូលហើយល្បីឈ្មោះពីនោះមក ។ ប៉ុន្តែ សៃយានខីស្មានខុសទៀតហើយ ! តៃហស៊ុក្អកខះៗមែន តែគាត់មិនភ្លេចប្រុងប្រយ័ត្នឡើយ កាលបើឃើញចាស់ត្រកូលសៃវាយចង្កេះជនត្រកូលមីគាត់ក្អកខះ ៗ ពោលថា :

– លោក . . . លោកសៃ . . . ខះ ! ខះ ! ធ្វើអ្វីចឹង ?

ពេលជង់លូកដៃទាំងពីរប្រាណទ្រូងជនសំគមនោះ ព្រមទាំងលើកជើងទល់ពោះទាល់តែជនត្រកូលនីចុះផុតក្បាលគាត់ ដាំជូនទៅជួលក្រោយខ្នងវិញ ហើយដៃទាំងពីរដែលប្រាណទ្រូងជនសំគមជ្រុលទៅសន្តំទ្រូងសៃយានខីវិញ ។ សៃយានខីឥតបានចាប់ភ្លឹកថា គ្រូពេទ្យដៃធេក ខះស្មៀតចំឡែក ទើបគេមតក្បាច់យ៉ាងទប់ទល់មិនបានក៏បណ្តោយឲ្យបាតដៃទាំងពីរប៉ះដៃគ្រូពេទ្យម្តង ។

រំពេចនោះ គាត់ទម្លាក់អារម្មណ៍ដូចមានប្តូលកម្ដៅទាន់បាត់ចុចបាតដៃ ចំងប្រមាណទាំងផង់ឈើស្រគៀរ ។ យានខីភ័យញ័ររំភើរកម្លាំងទប់ទល់គ្រាប់តែភ្ញាក់ព្រើតម្តងទៀត ព្រោះក្នុងខ្លួនរលីង

ពេញដូចស្គរប្រហោងក្នុង  គាត់ភ័យមែនទែនទឹកឃើញភ្លាម :

– អូយើងទើបហាត់វគ្គាថ្មីចំណាយកម្លាំងជិតអស់ហើយតើ ! ចុះម្ចឹង ៗ ទប់ទល់នឹងគេឯណាបាន ?

ទឹកឃើញដូច្នេះ  សិរិយានទីទម្លាក់ដៃវាយក្បាលពោះពៅហៃស៊ីវិញ ៗ  ពៅហៃស៊ីដកដៃស្ដាំទប់ទល់ភ្លាម,  សិរិយានទីរលាស់ដៃការប្រែស្នៀតបត់ខ្យល់តម្រង់មុខគូសត្រូវយ៉ាងសាហាវ ៗ ពៅហៃស៊ីនឹកក្នុងចិត្ត:

– ស្នៀតសាហាវមែន,  តែកម្លាំងអន់ណាស់ !

គាត់ដកដៃចេញហើយគេចមុខ,  សិរិយានទី បង្វិលខ្លួនថយក្រោយហើយលើកដៃគោរព :

– ប៉ុណ្ណឹងសិនចុះ,  ថ្ងៃក្រោយជួបគ្នាទៀត !

ពេលចប់ការក្រោយសម្រាលខ្លួនតាមសម្រួលចុះពីលើខ្នងគ្នា ៗ  ការនេះមិនអាចបញ្ជាក់ថាគាត់ចាញ់គេទេ  ព្រោះបើលេងមួយទល់នឹងមួយ គាត់អាចប្រហារសត្រូវបានខ្លះគ្រាន់លួងចិត្តដែរ ៗ  ពេលនេះការបេះទេសះមិនទាន់ហុចឲ្យ  ទើបគាត់ស្រុះចិត្តចុះចាញ់ក្នុំម៉ានដោយរីករាយ ៗ  ប៉ុន្តែមិនទាន់បានអីផង សិរិយានទីឈឺម្រាមដៃខ្លាំង ១  សម្លឹងមើលឃើញបាតដៃហើមក្រហមរលោង ក៏ភ្ញាក់ព្រើតនឹកថា :

– កញ្ចាស់គ្រូពេទ្យខ្មោចយក់នេះមានកម្លាំងជាតុស្ដុកស្ដម្ភណាស់តើ !  មិនកើតទេត្រូវរកកន្ទ្វីនព្យាបាលឲ្យបាត់ឈឺបាត់ហើមសិន ៗ

នៅលើក្នុំម៉ាន  ពៅហៃស៊ីកំពុងឆ្ងល់ថា  បើសិរិយានទីជាបក្ខរលោកនាយក្រុមយើងម្ដេចក៏គេចេះបាក់ក្នុំហើយចង់សម្លាប់ប្អូនដ៏ ?  រឿងនេះស្មុគស្មាញណាស់រកយល់មិនឃើញទេ ៗ

បន្ទាប់ពីនោះគាត់ប្រញាប់ប្រញាល់ទៅលើកគ្រាហ៍ជនសំគមជួយបញ្ចូលកម្លាំងមួយសន្ទុះ  ទើបជនគ្រូកូលដ៏បើកភ្នែកព្រឹម ៗ ពោលខ្សាវ ៗ :

– សូមអរគុណលោកគ្រូដែលបានជួយជីវិតខ្ញុំ ៗ

– សម្រាកបន្តិចសិនចុះ កុំកាលចំរើនកម្លាំងណា.

ត្បិតអម្បាញ់មិញ សិរិយានទីប្រាថ្នាចុះចង្កេះជនសំគមបន្ទាប់ផងវាយលុកពៅហៃស៊ីផង  បើពៅហៃស៊ីវាយជួបវិញនាំមុខត្រូវស្លាប់អសារបង់កណ្ដាលខ្យល់ដៃជនចាំងតែរ ។ ប៉ុន្តែគ្រូពេទ្យដៃជើងមានប្រាជ្ញាវាងវៃ  ទើបលើកជើងធ្លុះពោះជនគ្រូកូលទីប្រាក់គេ ។  ដើម្បីរំលាយកម្លាំងខ្យល់ដៃ

សេះយានទីនេះ រក្សាជីវិតជនត្រកូលនីឡគងវង់ផង ។ ជនសំគមហេវហត់ខ្សោយកម្លាំងណាស់ទាល់តែពៅហាស៊ីជួយរឹតច្របាច់ស្ពាបដើមទ្រូងទើបបានធូរ ។

ខណៈនោះឮសម្រែកនោះឡើងមកពីនាយថា:

– លោកនាយក្រុមនៅឯណោះ! រកលោកនាយក្រុមឃើញហើយកនយើង!

ពៅហាស៊ីរីករាយណាស់ថា:

– ប្អូននឹងចាកផុតពីគ្រោះថ្នាក់ហើយ , ខ្ញុំរត់ទៅមើលលោកនាយក្រុមសិនណា៎!

ពោលបណ្តើររត់សំដៅសម្លេងកោកកាកបណ្តើរនឹកថា:

–សាធុ! សាធុទៅលោកអើយ!· បើរកលោកនាយក្រុមមិនឃើញពួកយើងអស់មានឈ្មោះក្នុងពិភពគុនទៀតហើយ ។

មិនយូរប៉ុន្មាន ពៅហាស៊ីទៅដល់ជាយព្រៃតូចមួយ ឃើញបុរសម្នាក់អង្គុយពែនភ្នែនលើផ្ទាំងថ្ម មើលពីចំហៀងស្គាល់ជាក់ជានាយក្រុមរបស់គាត់តែម្ដង ។ បងប្អូនគាត់ទាំង៧នាក់ឈរសំយុងដៃគោរព ។ ពៅហាស៊ីរត់លះលោំងទៅជិតសម្ងឹងមើលផ្ទាល់ភ្នែក ។ នៅក្រោមពន្លឺព្រះអាទិត្យដែលចែងចាំងបកគាត់ឃើញភ្នែកធំពីរ, ចិញ្ចើមក្រាស់ឃ្មឹក, មុខពងក្រពើ ពិតជាលោកនាយក្រុមមែនហើយ ទើបស្រែកដោយអំណរ:

–លោកនាយក្រុម! លោកសុខសប្បាយទេឬ?

ខណៈនោះស្រាប់តែលោកនាយក្រុមប៉ិញាក់មុខព្រើត ១ ដោយការឈឺចាប់ប្ចាល់ម្ខាងឡើងទៀត ជាម្ខាងទៀតក្រហមឆេះដូចមនុស្សស្រវឹងស្រា ។ ពៅហាស៊ីស្គាល់អាការកេតគ្រប់ដុន ឃើញតែប៉ុណ្ណោះក៏ភ្ញាក់ព្រើត:

– លោកនាយក្រុមកំពុងហាត់ចំរើនកម្លាំងធាតុទេតើ? យើងមករំខានលោកទេដឹង? ទេ! លោកនាយក្រុមរើសបាននូវក្បួនយុទ្ធសិល្បៈក្វាម ស្រាប់តែបាត់ខ្លួនរហូតដល់ឥឡូវ ។ យើងស្វែងរកគ្រប់កន្លែងមិនប្រទះសោះ ចំណែកសេះយានទីប្រហែលដឹងការនេះបានជាមិនព្រមប្រាប់យើង ឬ? អើមែន! កញ្ចាស់នេះខ្លាចលោកនាយក្រុមបែកការម្ហណ៍ទេតើ , យើងតំហាំឲ្យគេអន់ចិត្តចុះពាក ក្នុងម៉ាឆានទៅបាត់ យ៉ាងនេះដូចជាជ្រុលពេកហើយ ។ លោកនាយក្រុមរវល់ហាត់រៀនឲ្យធាតុក្ដៅមិនត្រជាក់ប្រឆាំងគ្នាក្នុងខ្លួនលោកឯណោះសោះហ្ន! មិនស្រួលទេ តែបែកខ្វែកការម្ហណ៍អាចមាន

គ្រោះថ្នាក់ដល់ជីវិតផង ក៏សឹងមាន ។

ពៅហៃស៊ុយល់ឃើញថែបនេះទើបធ្វើសញ្ញាប្រាប់គ្នាថយឆ្ងាយ ដើម្បីពន្យល់ប្រាប់តាមដំណើររឿង ។ សមាជិកទាំង៧នាក់ភ័យផងអរផងសួរលាន់ :

- លោកនាយក្រុមមានគ្រោះថ្នាក់ទេ ?

- ហ៊ឺ ! យើងមិនគួរមករំខានលោកនាយក្រុមសោះ ទុកឲ្យលោកហាត់រៀនវិជ្ជាវិសេសបានសម្រេចដល់កំពូលវិញ ។

ពៅហៃស៊ុបញ្ជា :

- ប្អូនដ៏ត្រូវរបួសធ្ងន់ណាស់នៅសំពតកន្ទែងយើងប៉ុននោះ សូមនរណាម្នាក់ទៅជួយ លាងផង ។ ចំណែកគ្នាយើងខាងណេះត្រូវនៅចាំយាមលោកនាយក្រុមកុំឲ្យសត្រូវណាមករំខានឬបៀតបៀន ហើយសុំកុំមាត់នាំភ្ញាក់ផ្អើលលោកនាយក្រុម ។ បើមានសត្រូវក៏គួរវាយកំចាត់ដោយស្ងាត់ស្ងៀមផង ខ្ញុំនៅជិតនេះរង់ចាំការពារលោក ។

សមាជិកទាំង ៧ នាក់សុទ្ធសឹងជាអ្នកគុនខ្លាំងបណ្ដាប់ដឹងច្បាស់ណាស់ ថាការហាត់រៀនវិជ្ជាចំរើនកម្លាំងធាតុត្រូវប្រព្រឹត្តទៅដោយស្ងប់ស្ងាត់ បើពុំនោះទេ អ្នកហាត់រៀនទៀសមិនផុតគ្រោះថ្នាក់ឡើយ ម៉្លោះហើយគេស្ទុះស្ទាទៅយាមល្បាតលោកនាយក្រុមគ្រប់ច្រកល្ហក ។

ពៅហៃស៊ុំចូលមកជិតលោកនាយក្រុមមើលមុខម្ដងទៀត ។ លោកនាយក្រុមនៅតែញាក់សាច់ញ័រញើក ១ ដងដែល ហើយដូចជាហាមាត់ចង់ស្រែកហៅឲ្យគេជួយ លោកត្រូវពេទ្យដៃជើងភ័យ លោះព្រលឹងចង់ជួយណាស់ តែមិនដឹងលោកនាយក្រុមរៀនវិជ្ជាតាមច្រឹស្ដីអី ?

ពៅហៃស៊ុំមើលទៅពេលលោកនាយក្រុមម្ដងទៀតឃើញប្រឡាក់សុទ្ធតែដីនិងឈាម ហើយរាំហក់រង់ខ្លួនដូចលោកចុះនេរ ដោយ ខាការដាច់ស្បែកចេញឈាមដោយប្រការណាមួយ ។ ងើបមើលលើក្បាលត្រូវពេទ្យរឹតតែភ័យព្រោះឃើញផ្សែងពួយផុំក្រាស់ឃ្មុំកខ្យល់បក់ម៉េចបើនទៅណាសោះ ។ ពៅហៃស៊ុំនឹកថា : លោកនាយក្រុមមានវិជ្ជាប្លែកៗមែន តែកម្លាំងធាតុមិនជ្រៅជ្រះប៉ុន្មានទេ បើយោលតាមផ្សែងហុយលើក្បាលពេបមាត់ថាលោកមានកម្ដៅកាយខ្លាំងស្ទុកស្ទួណាស់ ហេតុអ្វីលោកហាត់រៀនរហ័សម៉្លេះ ? ពិតជាហាត់តាមក្បួនខ្នាតដ៏វិសេសនៃក្រុមណាមួយហើយ ។

កំពុងគិតពិចារណា ស្រាប់តែឮក្លិនឈ្ងៀមថ្លូវខ្លាចសាច់ ហើយឃើញផ្សែងហុយចេញពីភាវមក

ទៀត ៗ ពៅហស៊ុយល់គ្រោះអាសន្នរឹតតែភ័យព្រលឹងចុងសក់ប្រថុយលូកដៃចរដីពុចនាយក្រុម មួយពិបឲ្យភ្ញាក់ស្មារតី ៗ ប៉ុន្តែប៉ះសាច់លោកនាយក្រុមភ្លាម គ្រូពេទ្យញ័រចំប្រប់ត្រជាក់ស្រេបស្មើរ កកណាមហេតុមិនហ៊ានចំរើនកម្លាំងចប់ចល់សុខចិត្តដកថយក្រោយយ៉ាងប្រញាប់ ព្រមទាំងនឹកឆ្ងល់:

- លោកនាយក្រុមហាត់រៀនវិជ្ជាប្រភេទណា បានជាក្តៅមួយចំហៀងត្រជាក់មួយចំហៀង បែបនេះ ?

ពេលដែលគ្រូពេទ្យដើរគិតពុំគប់ប្រមល់ខ្វល់ខ្វាយចិត្ត, លោកនាយក្រុមស៊ីញ័រញាក់មែនទែន ហេតុដែលខ្លួនក្រញង់ធ្លាក់ពីលើផ្ទាំងថ្មខាងក ធាក់ជើងធាក់ដៃដូចមនុស្សឆ្កួតជ្រូក ៗ មួយស្របក់ ទើបលោកនាយក្រុមចុបក្បាលនៅស្ងៀមលែងកំរើក ៗ ពៅហស៊ុ ស្រែកហៅទាំងភ័យញ័រ :

- លោកនាយក្រុម ! លោកនាយក្រុម !

រួចស្ទុះទៅស្ទាបច្រមុះ ឃើញលោកនាយដកដង្ហើមដឹកៗដូចជិតដាច់ខ្យល់ ៗ ភ្លាមនោះ លោកនាយក្រុមស៊ីស្ទុះក្រោកស្រែកហួចធ្វេច, ពៅហស៊ីជួយគ្រាហ៍ឲ្យអង្គុយផ្អែកនឹងផ្ទាំងថ្មវិញ ៗ ពេលនោះសមាជិកទាំងឡាំងក្រុមឈានល្អ គេស្រមកមើលលោកនាយក្រុម ៗ គេភ័យស្លុតក្តគ្រប់គ្នាកាលបើឃើញទឹកមុខលោកនាយក្រុមដែលម្តងខៀវម្តងក្រហមញ័រជ្រើកដូចកូនសត្វគេងាកមើលមុខលោកគ្រូពេទ្យសួរបុព្វហេតុ ៗ ពៅហស៊ីតទ្យល់ :

- លោកនាយក្រុមមិនដឹងហាត់ចំរើនកម្លាំងតាមទ្រឹស្តីវិសេសណាមួយទេ ៗ ខ្ញុំមិនស្គាល់ ហើយមើលមិនយល់ឡើយ, ហេតុនេះសូមបងប្អូនជួយពិចារណា ហើយបញ្ចេញយោបល់ខ្លះផង ៗ

អ្នកទាំងអស់សម្លឹងមុខគ្នា នៅស្ងៀមមានន័យថា បើគ្រូពេទ្យដើរអស់មធ្យោបាយហើយពួកយើងក៏មិនដឹងធ្វើម៉េចដែរ ៗ ដងសំគបគ្រូវៈគជួយគ្រាហ៍ មកផ្អែកគល់ឈើក្បែរលោកនាយក្រុមស៊ី ពោលតិច ៗ :

- លោកគ្រូ....លោកគ្រូពិសម្រេចចិត្តចុះ យើងខ្ញុំចាំតែធ្វើតាមទេ ៗ

ពៅហស៊ីសម្លឹងមុខលោកនាយក្រុម សញ្ជឹងគិតមួយសន្ទុះ ទើបឆ្លើយ :

- ក្រុមបក្សធំ ៗ ទាំងប្អូននៅស្រុកត្បូងតុង បានណាត់គ្នាមកកាន់ដំរាំយើងនៅខែក្រោយនេះ ៗ ខ្ញុំយល់ថា ជាការបន្ទាន់ណាស់ ហើយទាក់ទងដល់កត្តិយសកត្តិនាម និងអាយុក្រុមបក្សផង អាយុ

ពួកយើងផង ព្រោះបងប្អូនយល់ស្រាប់ហើយ មិនមែនមានតែក្រុមប្អូនធំៗនោះទេ ច្បាស់ជាមានក្រុមបក្ស ផ្សេងទៀតទៅកាន់ជំរំយើងដែរ ។ បើពួកនោះរំលោភទីតាំងយើងឲ្យចាំផាដេះក្រុមឈានល្អមិនបាត់ឈ្មោះពីពិភពគុន ? ពួកយើងមិនបែកខ្ញែកគ្នា ?

សមាជិកមួយរូបត្រកូលយានបញ្ចេញយោបល់ :

– លោកគ្រូមានប្រសាសន៍ត្រូវណាស់ ។ ក្រុមឈានល្អធ្លាប់មានឈ្មោះល្បីក្នុងពិភពគុនជាចិត្តមុត , ក្លាហាន , ស្មោះត្រង់ណាស់ បានជាមានសត្រូវជុំវិញ ។ ឥឡូវគ្រោះថ្នាក់មកដល់ហើយ បើលោកនាយក្រុមមិនចាត់ការផ្ទាល់ទេ យើងគ្មានសង្ឃឹមរស់នៅតទៅទៀតទេ

ពៅហៃស៊ុបន្ត :

– ហេតុនេះយើងមិនត្រូវបង្អង់ឲ្យខាតពេលទេ ។ ខ្ញុំយល់ថាត្រូវប្រញាប់ដឹកនាំលោកនាយក្រុមទៅកន្លែងយើងព្យាបាលភ្លាម ។ ជម្ងឺនេះធ្ងន់ណាស់បើទេវតាជួយអាចជាឡើងវិញក្នុងរយៈពេល១០ថ្ងៃឬកន្លះខែ បើពុំនោះទេយើងត្រូវតាំងចិត្តមាំមួន តស៊ូដោយក្លាហានទៅណា ! មានលោកនាយក្រុមនៅជិតយើង, យើងមានកម្លាំងចិត្តខ្លះដែរមែនទេបងប្អូន ?

សមាជិកទាំងប៉ុន្មានងក់ក្បាលស្របគ្នាពោល:

– លោកគ្រូមានប្រសាសន៍ត្រូវហើយ ។

ពៅហៃស៊ុបន្តថា :

– បើស្រុះស្រួលគ្នាហើយ ត្រូវជួយធ្វើគ្រែស្នែងដឹកលោកនាយក្រុមនិងប្អូននី ទៅកាន់ជំរំយើងវិញ ។

គេនាំគ្នាទៅកាប់ដើមឈើមែកឈើនិងខ្សែវល្លិ៍ចេញបានគ្រែស្នែងពីរ លើកនាយក្រុមនិងជនសំគមដាក់លើនោះម្នាក់មួយហើយចងក្រៀកយ៉ាងជាប់ដើម្បីចុះពីភ្នំម៉ាធាន ។ សមាជិកទាំង ៨នាក់ផ្លាស់វេនគ្នាសែងគ្រែរហូតដល់ក្រោម ។

ថ្ងៃពីមាណពដែលហាត់រៀនតាមវិជ្ជាប្រាសាទដើងរបស់សៀយានទីគំណាច ។ នៅពេលថ្ងៃត្រង់នាយទទួលការម្ចាណ៍ដូចមានធាតុទៅជ្រាបចូលពេញខ្លួន ។ ក្នុងពេលជាមួយគ្នាមានធាតុត្រជាក់ជ្រាបចូលតាមសរសៃដីពចរដួបធ្លាក់ក្នុងសមុទ្រទឹកកក រងាញាក់ទទ្រើក ។ កម្មាះនេះព្យាយាមហាត់រៀនចង់ចូលដូចយានទីកំចេះរហ័សមែន ! រហ័សតាំងចិត្តសៀយានទីដែលប្រាថ្នាឲ្យ

នាយហាត់បានកម្លាំងក្ដៅស្មើកម្លាំងត្រជាក់ ដើម្បីឲ្យធាតុទាំងពីរនេះប្រឆាំងគ្នាក្នុងខ្លួនមាណពស្លាប់តែម្ដង ។

ថ្ងៃត្រង់ជាក់មាណពទំប្រឹងទប់ទល់នឹងអារម្មណ៍ចំឡែក គឺត្រជាក់ផងក្ដៅផង,ប្រហែលកន្លះម៉ោង នាយសន្លប់បាត់ស្មារតីតែម្ដង ។ ចាប់ពីពេលនោះមកនាយទទួលអារម្មណ៍ប្លែក ៗ រវើរវាយ ដូចធ្លាក់ក្នុងសមុទ្រទឹកកកកាំង ឈាមស្ទះដង្ហើម ដួនកាលដូចធ្លាក់ក្នុងខ្ទះប្រេងត្រូវភ្លើងក្ដៅពេលថែក ញើសស្រោក់ ស្ងួតបំពង់កចង់ស្រែកហៅគេជួយតែហាមាត់មិនកើត , ចង់បើកភ្នែកមើលគេ មើលមិនឃើញ ។ នៅជុំវិញនាយហាក់ឃើញមនុស្សប្រុសស្រីដើរទៅមក និយាយរកគ្រូហ៊ុះៗគ្នា តែនាយស្ដាប់ឥតឮសោះ ដួនកាលនាយឃើញដូចពន្លឺចាំងមុខព្រាល ៗ ដួនកាលងងឹតឈឹងចាក់ភ្នែកមិនធុះ ។

មានពេលខ្លះគេលើកក្បាលនាយបញ្ចុកនំចំណី និងគេសង្គះម្ដងផ្អែមម្ដងល្វីងមិនដឹងជាស្អីខ្លះទេ ។ នាយរស់នៅក្នុងសភាពរវើរវាយអស់ច្រើនថ្ងៃណាស់ទំរាំធូរស្រាលបានបន្តិច ។

ថ្ងៃនេះនាយបាត់អារម្មណ៍ហាក់ត្រជាក់ល្មមទ្រាំបាន នាយបើកភ្នែកព្រឹម ៗ ឃើញស្រមោលនារីម្នាក់ដើរចូលមកបោលក្លិនក្រអូបកាយ ។ កម្លោះបើកភ្នែកធំភ្ញាក់ស្មារតីភ្លាម ព្រោះឮនារីបន្លឺវាចាស្រួយស្រោក :

-អូ ! បងដឹងខ្លួនហើយតើ !

មាណពបែរមុខទាំងកម្លាស់សំឡេងឃើញនារីក្មេងខ្ចីអាយុប្រមាណ ១៥–១៦ឆ្នាំពាក់អាវពណ៌បៃតង មុខស្រស់ថ្លូវផង់ញញឹមរកនាយ ហើយនាងធ្វើភ្នែកក្រឡឹតក្រឡាប់សួរបៀមម៉ុកម៉ុក :

- នៅពិបាកត្រង់ណា, ឈឺត្រង់ណាទៀត ?

មាណពរកទឹកគ្មានឃើញអ្វីក្រៅពីពេលនាយកំពុងទំហាត់រៀនលើភ្នំយ៉ាន រូបព្រជាក់មួយចំហៀងខ្លួនក្ដៅមួយចំហៀងទ្រាំទ្រមិនបានទាល់តែសន្លប់បាត់ស្មារតីនោះទេ ។ នាយឆ្ងល់ណាស់ហេតុអ្វីមាននារីរូបស្អាតនៅជិតហើយនិយាយរកទៀត ? នាយស្ទាបស្ទង់បន្តិចដឹងខ្លួននៅដេកលើពូក ទន់ល្មើយ ដណ្ដប់ភួយយ៉ាងស្អាតគួរឲ្យកក់ក្ដៅ ។ នាយប្រឹងក្រោកអង្គុយស្រាប់តែឈឺចុកចាប់ពេញខ្លួនដូចគេយកម្ជុលចាក់សព្វសាច់កំរើកមិនរួចសោះ ។ ទ្រាំមិនបាននាយស្រែកយ៉ូយ ! នារីពោល :

- បងទើបនឹងធូរស្រាកស្រាន្តអំពីជំងឺ មិនត្រូវកំរើកផ្ដេសផ្ដាសទេ , សម្ងំឲ្យស្ងៀមយកកម្លាំងសិន

ទៅ ។ គុណបុណ្យលោកជួយហើយ បានជាបងគង់វង់ជីវិត ។

នារីពោលទាំងក្រហមមុខដោយក្តីអៀនខ្មាស បានតែប៉ុណ្ណឹងក៏ងាកមុខចេញភ្លាម ។ មាណពភ័យក្តុកក្តាក់ដោយចាប់ចិត្តស្រឡាញ់នារីរូបស្រស់ ។ នាយសួរ :

- ខ្ញុំ... ខ្ញុំនៅកន្លែងណា ?

នារីងាកមកវិញលើកម្រាមដៃផ្ទាប់បបូរមាត់មិនឲ្យនាយនិយាយ ហើយនាងនុនខ្សឹបប្រាប់ :

-គេមកហើយ ... ខ្ញុំសុំលា...

ពេលចប់នាងបង្វែរកាយចេញតាមបង្អួចរឹងបាត់ស្រមោល ។ មាណពនឹកស្តាយ ទសង្ស័យភាពនេះណាស់ដណ្តឹងសួរ :

-នារីនេះមកពីណា? គេមករកយើងទៀតទេ ?

ភ្លាមនោះនាយឮស្នូរជើងស្រាល ៗ តម្រង់មក ហើយឮក្អកខេះ ៗ ទើបទ្វារបន្ទប់បើកក្រាកលេចមនុស្សពីរនាក់ដើរចូលមក ។ ម្នាក់ជាតាចាស់មុខស្លេកស្លាំងហាក់មានជម្ងឺគ្រុនរ៉ែប្រចាំកាយ ម្នាក់ទៀតស្គមស្គុត , នាយបើកភ្នែកធំ ៗ ជ្រួញចិញ្ចើមរកនឹកដូចធ្លាប់ស្គាល់បុរសទាំងពីរនៅកន្លែងណា ។ តាចាស់ឃើញមាណពបើកភ្នែកបានក៏រីករាយណាស់ ខិតចូលមកជិតពោលទាំងអំណរ :

-លោកនាយក្រុមយ៉ាងម៉េចហើយ ? ថ្ងៃនេះទឹកមុខស្រស់បស់ជាងមុនច្រើន ។

មាណពឆ្លើយដោយស្ទាក់ស្ទើរ:

- ខ្ញុំ...ម៉េច...លោកហៅខ្ញុំ... នៅកន្លែងណា ?

តាចាស់បញ្ចេញទឹកមុខព្រួយបារម្ភមួយនាទីទើបញញឹមហើយសើចស្ងាញ :

- លោកនាយក្រុមឈឺប្រាំបីថ្ងៃហើយ ទើបតែដឹងខ្លួនថ្ងៃនេះគួរឲ្យយើងខ្ញុំរីករាយណាស់ ។ សូមលោកនាយក្រុមសំរាកកម្លាំងសិនចុះ, បន្តិចទៀតខ្ញុំបាទមកកំដរ ។

ពោលចប់គាត់លូកដៃចាប់ស្ទង់ជីពចរផង ងក់ក្បាលមួយៗបន្តវាចា :

-ជីពចរដើរស្រួលបួលបន្តិចហើយ គ្មានគ្រោះថ្នាក់ធំទេ ។ ហ៊ឺ ! ពិតជាទេវតាជួយយើងមែន ! ក្រុមបក្សយើងមានសុភមង្គលវិញហើយ !

មាណពទៅជាស្រឡាំងកាំងប្រកែកញាប់មាត់ :

-ខ្ញុំ...ខ្ញុំឈ្មោះវណ្ណតត្បូងមិនមែននាយក្រុមអីទេ ។

គាត់សំឡឹងជនស្លូតត្រង់មើលមុខគ្នារួចពោលថា :

-សូមលោកនាយក្រុមសំរាកកម្លាំងចុះ ។

ពោលហើយគាត់បបួលគ្នាដើរចេញទៅ ។ បុរសទាំងពីរគ្នានេះណា ក្រៅពីគ្រូពេទ្យវៃដេត វៃហាស៊ីនិងជនត្រកូលឌីឈ្មោះហ៊ីងយេខានក្រុមឈានល្អទេ ។ និហ៊ីងយេត្រូវរបួសដោយស្នាដៃសេរីយានខ្វីលើក្ដូម៉ាន បានគ្រូពេទ្យវៃដេតជួយព្យាបាលមិននាំមកទីតាំងទាន់ពេលវេលា តែនៅមិនទាន់អស់ចិត្តត្រង់ពាក្យប្រៀបគេគុនមួយស្មៀតជំនួស ។ វៃហាស៊ីជួយលួងលោមគាត់ :

-"រឿងហេតុអស់នេះសុទ្ធជាសំណាងយើងហើយ លោកប្អូនអើយ ! បើសេរីយានខ្វីភ័យបង្ក្រាបពួកយើងទាំង ៩ នាក់ ប្រហែលលោកនាយក្រុមមិនឈឺធ្ងន់ដល់ម្លឹងទេ ព្រោះខ្ញុំយល់ថាលោកនាយក្រុមរងគ្រោះ ដោយសារពួកយើងទៅរំខានលោកក្នុងពេលកំពុងប្រមូលអារម្មណ៍ហាត់រៀនវិជ្ជាចំបាប់គុនខ្លួន ។ ប៉ុន្តែសេរីយានខ្វីភ័យឲ្យរបួសធ្ងន់បងប្អូនឯងទាំងអស់គ្នាម៉្លេះគ្មានបានដើរតាមលោកសព្វគ្នាខ្លួនដែរ ។ ឥឡូវខូចការមួយផ្នែកធំហើយ ! ហ៊ឺ... បើលោកនាយក្រុមយ៉ាងម៉េចៗ ទៅ ប្អូនមានទោសស្រាលជាងគេ ព្រោះឥតបាននាំនៅលោកនាយក្រុម ។

និហ៊ីងយេតបដោយប្រញាប់:

- បងបានប្រកាសថាយ៉ាងនេះមិនត្រូវទេ ។ ខ្ញុំមិនបាននាំរំខានលោកនាយក្រុមមែន តែពួកយើងទាំង៩នាក់សុទ្ធជាសមាជិកក្រុមតែមួយ, ព្រោះបើយ៉ាងណាក៏ត្រូវសងគុណលោកនាយក្រុមឲ្យស្មើគ្នាដែរ ។ បើលោកនាយក្រុមមានគ្រោះថ្នាក់ធ្ងន់ទៅ យើងគោរពធ្វើអត្តឃាតចំពោះមុខលោកដើម្បីសងគុណលោកណា ! មែនទេបង ?

ការនេះបញ្ជាក់ថាសមាជិកក្រុមឈានល្អយកចិត្តទុកដាក់ជីវិតម្ចាស់លោកនាយក្រុមណាស់ ហើយមានចិត្តក្លាហានទទួលកំហុសម្ដង ១ គ្នា ។ គេនៅស្ងៀមប្រៀបចំពោះ...មុខចំឡែកបានជានិយាយគ្នាបែបហ្នឹង ។

អ្នកទាំងពីរផុតស្មានថាទេវតាជួយលោកនាយក្រុមឲ្យជាសះខ្លួនបើកភ្នែកនិយាយបាននៅថ្ងៃទី ៨ នេះ ។ គេកែតការប្ដូរ ១ គ្នា វៃហាស៊ី សួរអំពីអាការ លោកនាយក្រុម រាំញើរស្រួលគ្រាន់បើ គ្រូពេទ្យផុតខ្ពស់បម្រាប់តែលោកនាយក្រុមពោលពាក្យមួយម៉ាត់យ៉ាងចំឡែកធ្វើឲ្យគាត់ព្រឺខ្លួនបែកញើសស្រាក់ ទើបជាប់បបួលនិហ៊ីងយេចេញទៅវិញ ។ គ្រាន់តែផុតមាត់ទ្វារ និហ៊ីងយេស្អូរភ្លាម :

- មើចអីចឹង ?

តៃហាស៊ុនញញឹមតិច :

- លោកនាយក្រុមមិនស្គាល់យើងជាការធម្មតាទេ ព្រោះលោកសន្លប់យូរពេក, ត្រង់ថាលោកឈ្មោះវិទ្ធវេតគ្គង់វិញប៉ុន្តែជាថ្ងៃកំពេកណាស់ ប្រហែលវិលខួរក្បាលអស់ហើយដឹង ?

ប៉ុន្តែគាត់ពោលតបស្រួល :

- លោកនាយក្រុមយើងស្គាល់ស្នាដៃនៃទេកហើយ ៗ តែប៉ុណ្ណេះចាត់ទុកជាសំណាងហើយ កុំឲ្យតែសន្លប់រហូត ! តែរឿងយើងផ្តួលជាប្រញាប់ខ្លាំងណាស់ណា ! មិនដឹងលោកនាយក្រុមចាំបានកើត ឬទេ ?

បន្ទាប់ពីបុរសចំណាស់ចេញផុតទៅ មាណពបន្តេកបន្តិចម្តងទៀត ៗ នាយបើកភ្នែកមិនគេងអី ពីវត្សរ៍ព្រៃ បន្ទប់មានបង្អួចចំហរ ចាំពុំកន្លងស្រស់បំព្រង ឯកូនក្រមួនចេះតែផាត់មកជាទិចម្លូបស្អិតនៅស្លាបស្លឹកស្លូវស្បែបរីកណាស់ ។ ភ្លាមនោះនាយត្រលប់ភ្នែកបើលវែងឃើញរឿងទៀត នាយផកលៀមដឹងថា :

- យើងយល់សប្តិទេអី ?

ទឹកដប់នារីពាក់ពៅរ៉ែងនៃរាលពាក្យទន់ភ្លន់ ធ្វើយល់ថាមិនមែនយល់សប្តិទេ ៗ នាងមានចិត្តទៅប្រឡូងញ៉ុបស្រស់ត្រូវឲ្យចង់ឃើញ ៗ នាយបើកភ្នែកមើលបង្អួចឃើញពិចារនៅទៀយពីចំងាយនារីចាកចេញទៅវែងទេ នាយលើកដៃខ្ទាស់ស្ទាបក្បាលក៏ឈឺពេញខ្លួនស្រែកយ៉ូយម្តងទៀត ។ ខណៈនោះមានសម្លេងស្លាបហើរៗនៅកៀនជញ្ជាំងហើយស្ត្រីម្នាក់សួរ :

-អ្នកប្រុស...អ្នកប្រុសដឹងខ្លួនហើយ !

សម្លេងនេះមិនសូវលឺ ហាក់មិនទាន់ស្គាល់មែនទែន ៗ បន្ទាប់មកទើបស្ត្រីលាន់មាត់ម្តងទៀតទាំងភាគភ័យ :

- អ្នកប្រុសដឹងខ្លួនហើយ !

មាណពបើកភ្នែកព្រឹប ១ ឃើញនារីអាវលឿងស្ទុះពីកៀនជញ្ជាំងតម្រង់មកព្រៃ ៗ មុននឹងជូននាយស្គាល់ថានារីដែលត្រឡប់មកខាយវិញទើបត្រេកអរទំបើកភ្នែកមើលនាង ៗ

# វគ្គទី ៨

## គំនុំជ័រជ្រាវ

លុះពិនិត្យមើលទៅឃើញនាងពាក់ការវ៉ៃទិពណ៌លឿងខ្ចី មុខមូលភ្នែកធំៗ តែស្រស់ណាស់ដែរ ។ នាងមកដល់ក្បាលខ្នងតិចៗ

- អ្នកប្រុស... អ្នកប្រុសជាហើយឬ ?

មាណពពោលតិចៗ :

- ខ្ញុំដឹងខ្លួនហើយ... អម្បាញ់មិញខ្ញុំយល់សប្តិ :

- ប្រហែលអ្នកប្រុសយល់សប្តិមែនទេដឹង ?

ពោលបានត្រឹមណោះនាងខ្ទប់មាត់ឈប់និយាយ ហើយរៀបចំទឹកមុខម៉ាំទាំសួរដោយគោរព :

- ពេលនេះអ្នកប្រុសត្រូវការអ្វីដែរ ?

- ឯងហៅខ្ញុំថាម៉េច ? អ្នកប្រុសអី ?

នារីប្រែទឹកមុខជាខឹង:

- ខ្ញុំជាមនុស្សទាបថោកត្រូវហៅអ្នកប្រុសអ៊ីចឹងហើយ !

មាណពពោលរអ៊ូតែឯង :

- អម្បាញ់មិញគេហៅ «លោកនាយក្រុម» ឥឡូវគេហៅអ្នកប្រុស . . . ស្អីអ៊ីចេះហ្ន៎ ! ខ្ញុំជាអ្នកណា ? ហេតុអីមកដល់ទីនេះ ?

នារីពោលដោយស្រួល:

- អ្នកប្រុសមិនទាន់ស្រួលខ្លួនមែនទែនទេ, សូមសំរាកទៀតចុះ ។ អ្នកប្រុសចង់ពិសាសម្លលើកម៉ាំងទេ ?

មាណពធ្វើភ្នែកស្ងឹតយល់អីសោះ, នារីសួរបញ្ជាក់ :

- សម្លប៉ូវណា ! អ្នកប្រុសត្រូវការទេ ?

(នៅមានត)

Khmer Story Lovers

ដឹកល់ខុតតាមលេខ ២៩៣ ចុះថ្ងៃទី ១៥-៥-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់